# បាគ (បាស) នៅក្នុងសិល្បៈខ្មែរ

ជាទូទៅ បដិមា ឬចម្លាក់អាទិទេពក្នុងព្រហ្មញ្ញសាសនាសិល្បករតែងឆ្លាក់កាន់កេតនភណ្ឌ និងយានជំនិះលើសត្វផ្សេងៗ។ ឧទាហរណ៍ គេឆ្លាក់ព្រះវិស្ណុមានយានជំនិះជាសត្វគ្រុឌ ហើយកាន់កេតនភណ្ឌសំខាន់ៗមួយចំនួនដូចជា ដុំមូល ដំបង កងចក្រ ខ្យងស័ង្ខ។ រីឯ ព្រះឥសូរវិញ មានយានជំនិះសត្វគោនន្ទិ និងមានកេតនភណ្ឌដូចជា ត្រីសូល៍ ថូ ស្គរ ផ្តាំ ខ្សែ លលាដ៍ក្បាល។ ការឆ្លាក់ចេញកេតនភណ្ឌទាំងនេះ ពុំមែនជាការចៃដន្យនោះឡើយ ពោល គឺសិល្បករឆ្លាក់ត្រាប់តាមគម្ពីរបុរាណរបស់ព្រហ្មញ្ញសាសនាដែលគេតាក់តែងឡើង។ ដោយឡែក នៅក្នុងអត្ថបទខ្លីនេះយើងសូមលើកឡើងអំពីកេតនភណ្ឌមួយរបស់ព្រះវរុណដែលមានឈ្មោះថា "បាគ" (បាស)។ ព្រះវរុណ គឺជាទេពតំណាងឱ្យទឹកឬសមុទ្រ និងជាលោកបាលប្រចាំនៅទិសខាងលិច។ នៅសម័យវេទវរុណមានយានជំនិះជាសត្វមករ តែក្រោយមកនៅពេលឥទ្ធិពលរបស់ទ្រង់ថយចុះទ្រង់បានប្តូរមកជិះសត្វហង្សជាយានជំនិះវិញ។[១] តើបាគមានអត្ថន័យយ៉ាងណាខ្លះ និងបាគនៅក្នុងសិល្បៈខ្មែរសិល្បករឆ្លាក់បង្ហាញយ៉ាងណាដែរ?

បាគ គឺជាពាក្យសំស្ក្រឹតដែលប្រែមកជាភាសាខ្មែរថា "ខ្សែ" ហើយជាទូទៅគេប្រើប្រាស់បាគដើម្បីចងជើងនិងដៃរបស់គូសត្រូវ ឬចាប់សត្វ។[២] ផ្ទុយទៅវិញ នៅក្នុងព្រហ្មញ្ញសាសនាគេចាត់ទុកបាគគឺជាអាវុធរំពាត់ខ្សែតីដ៏ពិសិដ្ឋ ដែលជាទូទៅមានទេពចំនួនបីដែលយកបាគជាអាវុធ រួមមានព្រះវរុណ ព្រះយម និងព្រះគណេស។ លោក Ananda Coomaraswamy យល់ថា បាគ តំណាងឱ្យការតភ្ជាប់ខ្សែរវាងអាទិទេពជាមួយពិភពលោក និងជាចំណងអំណាចសម្រាប់ចាប់យកអំពើអាក្រក់ និងភាពល្ងង់ខ្លៅ។[៣] ព្រះគណេស ប្រើប្រាស់អាវុធនេះដើម្បីចងនិងដោះលែងនូវឧបសគ្គទាំងពួងដែលមនុស្សបានប្រព្រឹត្តឡើង ព្រោះព្រះគណេសមានតួនាទីអ្នកបណ្តេញឧបសគ្គនៅក្នុងព្រហ្មញ្ញ សាសនា។[៤] ចំណែក ព្រះយមវិញគេប្រើប្រាស់បាគដើម្បីទាញយកព្រលឹងចេញពីរាងកាយរបស់សត្វលោកនៅពេលស្លាប់ ព្រោះទ្រង់គឺជាអាទិទេពនៃសេចក្តីស្លាប់។[៥] នៅក្នុងនិកាយ Shaiva Siddhanta បាគ គឺជាផ្នែកមួយនៅក្នុងអាទិទេពទាំងបី ដែលមានឈ្មោះថា "**បតិ-បសុ-បាគ**" (Pati-Pashu-Pāsha) មានន័យថា "**អ្នកគ្រប់គ្រង, សត្វ, ចំណង**" ដែលជានិម្មិតរូបរបស់

---

[១] Roveda 2005.

[២] Guénon 2004.

[៣] Guénon 2004.

[៤] Jansen 1993.

[៥] Lochtefeld 2002.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

អាទិទេព មនុស្ស និងលោក[1]។ ក្នុងនោះ "បតិ" សំដៅទៅលើព្រះឥសូរ ដែលជាអាទិទេពបង្កើតនិងបំផ្លាញលោក។ "បសុ" សំដៅទៅលើព្រលឹង អាត្ម័ន ឬមនុស្ស។ ចំណែក "បាគ" គឺសំដៅដល់អំណាចដែលព្រះឥសូរនាំយកព្រលឹងទៅកាន់សេចក្តីពិត ឬអំណាចមាយ (Maya) របស់ទ្រង់។

នៅសម័យមុនអង្គរ ប្រវត្តិសិល្បៈវិទូជាច្រើនពិបាកក្នុងការកំណត់រូបរាងព្រះវរុណណាស់ ម៉្លោះហើយ យើងមិនមានភស្តុតាងបង្ហាញអំពីអាវុធរំពាត់ខ្សែតី ឬខ្សែអន្ទាក់ ដែលហៅថា "បាគ" របស់ព្រះវរុណដូចគ្នា។ ប៉ុន្តែ មកដល់សម័យអង្គរ ជាពិសេសចាប់ពីស.វ.ទី១០មក ការឆ្លាក់រូបព្រះវរុណមានភាពនិយមខ្លាំងណាស់ ព្រោះទ្រង់គឺជាលោកបាលប្រចាំទិសខាងលិច ម៉្លោះហើយ យើងអាចមើលឃើញចម្លាក់ព្រះវរុណជាច្រើននៅតាមហោជាង ផ្តែរ ឬជាបដិមាទោលក៏មាន។ រូបលេខ២១ រកឃើញនៅប្រាសាទក្រចាប់ តំបន់ប្រាសាទកោះកេរ ខេត្តព្រះវិហារ បង្ហាញអំពីហោជាងមួយដែលមានចម្លាក់ទេពព្រះវរុណអង្គុយនៅលើហង្សចំនួនបី អមដោយថូផ្កាចំនួនពីរ ហើយព្រះហស្តឆ្វេងដាក់នៅលើភ្លៅ និងព្រះហស្តស្តាំកាន់អាវុធរំពាត់ខ្សែតី ដែលហៅថា បាគ។ ព្រះវរុណកាន់អាវុធនេះសម្រាប់ចាប់ចងអំពើអាក្រក់ដែលជនទុច្ចរិតបានប្រព្រឹត្ត ព្រោះទ្រង់គឺជាអាទិទេពនៃគ្រោះថ្នាក់ មានវេទមន្តនិងអំណាចដ៏អស្ចារ្យសម្រាប់ដាក់ទណ្ឌកម្មមនុស្សអាក្រក់[2]។ ចម្លាក់បាគដែលបង្ហាញក្នុងរូបលេខ២១នេះ មានទម្រង់ជាខ្សែវេញដែលមានដងកាន់ និងផ្នែកខាងលើក្រងវេញចូលគ្នាចេញជារាងមូល។ ក្រៅពីនេះ នៅប្រាសាទបន្ទាយស្រី សិល្បករនិយមឆ្លាក់រូបព្រះវរុណខ្លាំងណាស់ ពោល គឺចម្លាក់ដែលនៅទិសខាងលិចមានរូបព្រះវរុណច្រើន ជាពិសេសគឺនៅលើផ្តែរទ្វារនិងហោជាង។ ក្នុងនោះ យើងសង្កេតឃើញចម្លាក់ព្រះវរុណចំនួនបួន តែពីររូបក្នុងចំណោមនោះរលុបចម្លាក់បាគបាត់ទៅហើយ (រូបលេខ២២-៣)។ ចម្លាក់ព្រះវរុណកាន់បាគចំនួនពីរដែលនៅសល់ មានលក្ខណៈស្ទើរតែដូចគ្នាជាមួយរូបព្រះវរុណកាន់បាគដែលរកឃើញនៅប្រាសាទក្រចាប់ដូចបង្ហាញនៅរូបខាងលើ គ្រាន់តែនៅប្រាសាទបន្ទាយស្រីមានរូបមួយគេឆ្លាក់ព្រះវរុណជិះលើសត្វហង្សចំនួនមួយប៉ុណ្ណោះ (រូបលេខ២៤-៥)។ ក្រៅពីរូបដែលបង្ហាញខាងលើទាំងអម្បាលម៉ាន នៅមានរូបព្រះវរុណជាច្រើនទៀតដែលយើងមិនបានយកមកបង្ហាញ ព្រោះថានៅសម័យអង្គររូបចម្លាក់របៀបនេះមានភាពសម្បូណ៌ខ្លាំងណាស់ ឧទាហរណ៍ រូបព្រះវរុណកាន់បាគឆ្លាក់នៅលើផ្តែរទ្វារប្រាសាទមេបុណ្យខាងកើតជាដើម (រូបលេខ២៧)។

[1] Subramuniya 2000.
[2] Roveda 2005.

ចម្លាក់បាគនៅក្នុងសិល្បៈខ្មែរ មានលក្ខណៈស្រដៀងចម្លាក់បាគនៅក្នុងសិល្បៈឥណ្ឌាដែរ ប៉ុន្តែចំណុចដែលខុសគ្នាតិចតួចនោះគឺ ចម្លាក់បាគនៅសិល្បៈឥណ្ឌាមួយចំនួនគេនិយមឆ្លាក់ឱ្យមានខ្សែកាន់វែងៗ ហើយចំណងដែលគេវេញឱ្យចេញរាងមូលនៅផ្នែកខាងលើនោះក៏មានប្រវែងធំៗដូចគ្នាដែរ (រូបលេខ៨-៩)។

ជារួមមក ចម្លាក់បាគ គឺសំដៅដល់រំពាត់ខ្សែតីដែលយើងតែងឃើញគេឆ្លាក់នៅជាប់នឹងព្រះហស្តព្រះវរុណនៅក្នុងសិល្បៈខ្មែរ ដែលមានន័យថា អាវុធសម្រាប់ចាប់ និងចងអំពើបាបទាំងឡាយណាដែលជនទុច្ចរិតបានប្រព្រឹត្ត ដ្បិតក្រៅពីមានតួនាទីជាទេពនៃទឹកឬសមុទ្រ ព្រះអង្គក៏ជាទេពនៃសេចក្តីគ្រោះថ្នាក់ផងដែរ។ ចម្លាក់បាគ ស្តែងឱ្យឃើញនូវការចេះដឹងជ្រៅជ្រះនូវគម្ពីរនិងក្បួនខ្នាតនៃព្រហ្មញ្ញសាសនាដែលខ្មែរសម័យបុរាណបានគោរពប្រតិបត្តិ ហើយចម្លាក់ទាំងនេះគឺជាតឹកតាងមួយដែលឱ្យអ្នកសិក្សាស្រាវជ្រាវអាចកំណត់បានថាជាអ្វី? ឬជាអាទិទេពអង្គណាដែលកាន់ចម្លាក់នេះ៕

## ឯកសារយោង


**Guénon, René**

2004, *Symbols of sacred science*, Sophia Perennis.

**Jansen, Eva Rudy**

1993, *The book of Hindu imagery: Gods, manifestations and their meaning,* Bingkey Kok Publications.

**Lochtefeld, James G.**

2002, "Păsha", *The illustrated encyclopedia of Hinduism*, N-Z, The Rosen Publishing Group.

**Roveda, Victorio**

2005, *"Image of the god"*, River Book, Bangkok.


KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១១៖ ចម្លាក់ព្រះវរុណគង់បាគនៅលើហោជាងប្រាសាទក្រចាប់ (រូបថត៖ គុំ រតនៈពិសិដ្ឋ)





រូបលេខ១២-១៣៖ ចម្លាក់ព្រះវរុណគង់បាគនៅប្រាសាទបន្ទាយស្រី (រូបថត៖ លីម ប៊ុនហុង)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៤៖ ចម្លាក់ព្រះវារុណកាន់បាគនៅប្រាសាទបន្ទាយស្រី (រូបថត៖ លីម ប៊ុនហុង)



រូបលេខ២៥៖ ចម្លាក់ព្រះវារុណកាន់បាគនៅប្រាសាទបន្ទាយស្រី (រូបថត៖ លីម ប៊ុនហុង)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៦៖ ចម្លាក់ព្រះវរុណកាន់បាគនៅប្រាសាទមេបុណ្យខាងកើត (រូបថត៖ កុំ រតនៈពិសិដ្ឋ)





រូបលេខ២៧-៨៖ ចម្លាក់ព្រះវរុណកាន់បាគនៅប្រាសាទ Karnataka និង Rajarani

(រូបថត៖ http://hindugod99.blogspot.com/2014/03/lord-varuna-god-of-water.html)

(https://www.reddit.com/r/hinduism/comments/mj7fjd/image_of_lord_varuna_from_rajarani_temple)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី